ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

# គម្រោងអាជីវកម្ម
# កែច្នៃត្រីខៀត



រៀបចំដោយ

**នាយកដ្ឋានគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ**
**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB)**

ខែកក្កដា ឆ្នាំ២០២៦

**មាតិកា**

**១-សេចក្តីផ្តើម** ........................................................................................1
**២-បច្ចេកទេសកែច្នៃត្រីងៀត** ......................................................................1
២.១. ការជ្រើសរើស និងគ្រប់គ្រងវត្ថុធាតុដើម........................................................1
២.២. ការកាត់ក្បាល វះ និងលាងសម្អាត ..................................................................2
២.៣. ការប្រឡាក់ និងត្រាំគ្រឿង..................................................................................4
២.៤. រយៈពេល និងសីតុណ្ហភាពនៃការត្រាំគ្រឿង......................................................5
២.៥. ការហាលសម្ងួត ..................................................................................................6
២.៦. ការត្រួតពិនិត្យគុណភាព ....................................................................................7
២.៧. ការវេចខ្ចប់..........................................................................................................7
២.៨. ការរក្សាទុក.........................................................................................................8
**៣-គម្រោងអាជីវកម្មកែច្នៃត្រីងៀត** ...........................................................................8
៣-១- គម្រោងកែច្នៃត្រីងៀត..........................................................................................8
៣-២- ការវិភាគសេដ្ឋកិច្ចក្នុងការកែច្នៃត្រីងៀតក្នុង១វគ្គ ................................................9
៣-៣- ការវិភាគលទ្ធផលដោយផ្អែកលើតម្លៃលក់ .........................................................10
៣-៤- ខ្សែច្រវាក់តម្លៃ ..................................................................................................11
**៤-ហានិភ័យ និងបញ្ហាប្រឈម** ..................................................................................11
**៥-សេចក្តីសន្និដ្ឋាន** ......................................................................................................13
**ប្រភពសិក្សាស្រាវជ្រាវ** ..............................................................................................14

## ១-សេចក្តីផ្តើម

តម្រូវការចាំបាច់ដែលមិនអាចខ្វះបានរបស់ប្រជាជនកម្ពុជាក្នុងរបបអាហារប្រចាំថ្ងៃនោះគឺការបរិភោគទាំងត្រីស្រស់ និងផលិតផលកែច្នៃពីត្រីដូចជា ប្រហុក ផ្អក ត្រីឆ្អើរ ត្រីងៀត។ល។ ដែលជាទម្លាប់នៃការបរិភោគដ៏ពេញនិយម។ តម្រូវការផលិតផលត្រីងៀតនៅលើទីផ្សារមានការកើនឡើងជារៀងរាល់ថ្ងៃ នាំឱ្យប្រជាជនយើងមួយចំនួនបានចាប់យករបរកែច្នៃត្រីងៀត ដែលអាចជួយសម្រួលដល់ជីវភាពរស់នៅប្រចាំថ្ងៃ។ ការកែច្នៃធនធានជលផលគឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងការជួយជំរុញកំណើនសេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិ។ ទោះជាយ៉ាងណា ការធ្វើត្រីងៀតជាលក្ខណៈគ្រួសារភាគច្រើននៅមានកម្រិតលើផ្នែកអនាម័យ ការវេចខ្ចប់ និងការរក្សាគុណភាពឱ្យបានយូរអង្វែង។ ហេតុនេះ ទើបការសិក្សាស្រាវជ្រាវពីគម្រោងអាជីវកម្មនេះ ត្រូវបានរៀបចំឡើងដើម្បីសិក្សាអំពីច្រវាក់ផលិតកម្មនៃការកែច្នៃត្រីងៀត តាមស្តង់ដារសុវត្ថិភាព ដែលរួមបញ្ចូលទាំងការជ្រើសរើសវត្ថុធាតុដើម បច្ចេកទេសសម្ងួតប្រកបដោយអនាម័យ និងការវេចខ្ចប់តាមបែបបច្ចេកវិទ្យាថ្មី ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារបច្ចុប្បន្ន និងការនាំចេញ។

## ២-បច្ចេកទេសកែច្នៃត្រីងៀត

### ២.១. ការជ្រើសរើស និងគ្រប់គ្រងវត្ថុធាតុដើម

គុណភាពត្រីជាអ្នកកំណត់រហូតដល់ ៨០% នៃគុណភាព រសជាតិ និងអាយុកាលរក្សាទុករបស់ត្រីងៀត។ ប្រសិនបើជ្រើសរើសត្រីមិនបានល្អ ច្រវាក់ផលិតកម្មបន្ទាប់ៗ ទោះជាធ្វើបានស្អាតយ៉ាងណាក៏ដោយក៏មិនអាចទទួលបានត្រីងៀតដែលមានស្តង់ដារខ្ពស់ដែរ។

❖ **ប្រភេទត្រី និងគុណភាព÷** ប្រភេទត្រីដែលនិយមជ្រើសរើសយកមកការកែច្នៃ មានត្រីឆ្តោ ឬត្រីរ៉ស់ ដែលមានស្តង់ដារគុណភាពត្រឹមត្រូវ រួមមានដូចខាងក្រោម÷

- **រូបរាងខាងក្រៅ÷** ស្បែកត្រីមានសភាពរលោង ស្រកាជាប់ស្អិតមិនរបូត និងមិនមានស្លាកស្នាមរបួស បាក់ឆ្អឹង និងមិនមានប៉ារ៉ាស៊ិតតោងជាប់។
- **ភ្នែកត្រី÷** ខ្មៅថ្លា រស់រវើក និងប៉ោងចេញមកខាងក្រៅ (មិនល្អក់ មិនស្រអាប់ និងមិនផតចូលក្នុង)។
- **ស្រកី÷** មានពណ៌ក្រហមស្រស់ ឬក្រហមឈាមជ្រូក មិនមានទឹករំអិលស្អិតខ្លាំង និងមិនមានក្លិនស្អុយភាយចេញ។
- **សាច់ត្រី÷** មានភាពណែន និងយឺត នៅពេលយកម្រាមដៃសង្កត់ទៅលើសាច់ត្រី ពេលដកដៃចេញសាច់ត្រីមកសភាពដើមវិញភ្លាមៗ ដោយមិនបន្សល់ស្នាមផតឡើយ។
- **ក្លិន÷** មានក្លិនឆ្អាបស្រាលតាមធម្មជាតិ មិនមានក្លិនស្អុយ ជូរ។

❖ **ការគ្រប់គ្រងប្រភពផ្គត់ផ្គង់÷** ដើម្បីធានាបាននូវបរិមាណផលិតផលថេរ និងតម្លៃប្រកួតប្រជែង ម្ចាស់សហគ្រាស ឬសិប្បកម្មកែច្នៃត្រូវរៀបចំផែនការប្រមូលទិញវត្ថុធាតុដើម។

- **ការជ្រើសរើសដៃគូ៖** គួរចងក្រងបណ្តាញជាមួយវារីវប្បករ ឬភ្នាក់ងារប្រមូលទិញដុំដែលគួរឱ្យទុកចិត្ត។ ការទិញផ្ទាល់ពីស្រះចិញ្ចឹម ជួយឱ្យដឹងពីប្រវត្តិចំណី និងការប្រើប្រាស់ថ្នាំកសិកម្មផ្សេងៗលើត្រី។
- **ភាពស្មើគ្នានៃទំហំ៖** ត្រីដែលប្រមូលទិញក្នុងមួយឡូតិ៍ ឬស្រះ ភាគច្រើនមានទំហំ និងទម្ងន់ប្រហាក់ប្រហែលគ្នា។ ភាពស្មើគ្នានេះមានភាពងាយស្រួលក្នុងការគណនារូបមន្តប្រឡាក់គ្រឿង និងធ្វើឱ្យត្រីស្ងួតស្មើគ្នាល្អនៅពេលហាល។

❖ **ការដឹកជញ្ជូន និងរក្សាទុក៖** មេរោគ និងបាក់តេរីចាប់ផ្តើមលូតលាស់ភ្លាមៗនៅពេលត្រីងាប់ ដូចនេះ ការដឹកជញ្ជូន និងការរក្សាទុកបណ្តោះអាសន្នត្រូវធ្វើឡើងប្រកបដោយបច្ចេកទេស។

- **ការគ្រប់គ្រងសីតុណ្ហភាព៖** ក្នុងករណីប្រមូលទិញត្រីដែលងាប់ភ្លាមៗពីប្រភពឆ្ងាយ ត្រូវដឹកជញ្ជូនដោយប្រើធុងទឹកកកដែលរក្សាសីតុណ្ហភាពចន្លោះពី ០ ដល់ ៤°C។
- **ការដឹកជញ្ជូនត្រីរស់៖** វិធីសាស្ត្រដ៏ល្អបំផុតសម្រាប់អាជីវកម្មខ្នាតមធ្យម ការដឹកជញ្ជូនត្រីទាំងរស់ដោយមានប្រព័ន្ធអុកស៊ីសែនមកដល់ទីតាំង រួចដាក់ក្នុងអាងស្តុកបណ្តោះអាសន្ន និងធ្វើការវះកាត់កែច្នៃភ្លាមៗ ដើម្បីធានាបាននូវភាពស្រស់ស្អាតបំផុត។





## ២.២. ការកាត់ក្បាល វះ និងលាងសម្អាត

ការកាត់ក្បាល វះកាត់ និងលាងសម្អាតត្រី គឺជាដំណាក់កាលដ៏សំខាន់មួយ បើធ្វើមិនបានត្រឹមត្រូវទេ ត្រីងៀតនឹងមានក្លិនឆ្អាប ខ្មៅសាច់ និងឆាប់ដុះផ្សិត ឬខូចគុណភាព។ ជំហាននៃការវះកាត់ត្រីសមស្របតាមបច្ចេកទេសកែច្នៃស្តង់ដារអនាម័យ និងរក្សាបាននូវសោភ័ណភាពសាច់ត្រី រួមមាន៖

❖ **ការរៀបចំសម្ភារៈ និងឧបករណ៍៖** មុននឹងចាប់ផ្តើម ត្រូវធានាថាឧបករណ៍ កម្លាំងពលកម្ម និងដៃរបស់អ្នកវះកាត់ត្រីមានអនាម័យត្រឹមត្រូវ។

- **សម្ភារៈ/ឧបករណ៍៖** កាំបិត (ត្រូវមុតល្អ ដើម្បីកុំឱ្យសាច់ត្រីរហែក) ជ្រុញ កន្ត្រក ធុងជ័រ/ដែក សម្រាប់លាងសម្អាត។

- **ទឹកសម្អាត៖** ត្រូវប្រើទឹកស្អាត លាយជាមួយអំបិលបន្តិច (កំហាប់ ១-២%) ដើម្បីជួយជម្រះរំអិល និងឈាម។

❖ **ការធ្វើស្រកា និងកាត់ក្បាលត្រី៖**

- **ធ្វើស្រកា៖** ប្រើកាំបិតរុះស្រកាត្រីពីខាងកន្ទុយឡើងមកក្បាលឱ្យបានស្អាតល្អទាំងផ្នែកខ្នង និងពោះត្រី។
- **កាត់ព្រុយ៖** ប្រើកាំបិត ឬកន្ត្រៃធំ កាត់ព្រុយខ្នង ព្រុយពោះ និងព្រុយចំហៀងចេញ។
- **កាត់ក្បាល៖** កាត់ជាទម្រង់អក្សរវី “V” ដោយដាក់កាំបិតនៅចំណុះក្រោយព្រុយចំហៀង រួចអូសកាំបិតឆ្ពោះទៅរកក្បាលត្រី និងសង្កត់កាំបិតទំលុះឆ្អឹងក្បាល រួចទាញផ្តាច់ក្បាលចេញ វិធីនេះនឹងរក្សាបានសាច់ស្មា និងសាច់ពោះត្រីបានច្រើនបំផុត។
- **វះបើកសាច់តាមខ្នង៖** វះទំលុះពីផ្នែកក្បាលអូសតាមបណ្តោយឆ្អឹងខ្នងរហូតដល់ចុងកន្ទុយ។ ត្រូវអារឱ្យជ្រៅដល់ឆ្អឹងជំនី ប៉ុន្តែកុំឱ្យធ្លាយស្បែកពោះខាងក្រោម។
- **យកឆ្អឹងកណ្តាលចេញ៖** ភាគច្រើនលះយកឆ្អឹងកណ្តាលចេញពាក់កណ្តាល (ចាប់ពីក្បាលដល់ត្រឹមផ្ចិតត្រី) ដោយទុកតែឆ្អឹងកន្ទុយបន្តិចដើម្បីទប់រាងត្រី។ ប្រើកាំបិតលះខ្សៀលក្រោមឆ្អឹងខ្នង រួចកាត់ផ្តាច់ឆ្អឹងនោះចេញ។
- **ការសម្អាតគ្រឿងក្នុង និងសរសៃឈាម៖** បើកសាច់ត្រីដែលវះរួចជាពីរ (រាងមេអំបៅ) ចាប់ទាញពោះវៀន ក្រពះ ថ្លើម និងប្រមាត់ចេញទាំងអស់។ ត្រូវប្រុងប្រយ័ត្នកុំឱ្យបែកថង់ប្រមាត់ បើបែក សាច់ត្រីនឹងល្វីង និងឡើងពណ៌លឿង។ ប្រើកាំបិតកោសសរសៃឈាមខ្មៅ (ឈាមកក) ដែលរត់តាមបណ្តោយឆ្អឹងខ្នងចេញឱ្យអស់។






- **ឆ្វឹតសាច់ជាឆ្នូត៖** ត្រីរ៉ស់ ឬត្រីឆ្តោធំៗ សាច់ក្រាស់ ត្រូវឆ្វឹតជាឆ្នូត ដើម្បីជួយកាត់បន្ថយរយៈពេលត្រាំអំបិល ឬប្រឡាក់គ្រឿង។

❖ **ការលាងសម្អាត÷** ត្រូវធ្វើឡើងពី ៣ ទៅ ៤ ទឹក ដើម្បីធានាថាត្រីស្អាតល្អ

- **ទឹកទី ១ (លាងជម្រះរំអិល និងឈាមដំបូង)÷** លាងត្រីក្នុងទឹកស្អាតធម្មតា ដើម្បីជម្រះកំទេចស្រកា គ្រឿងក្នុង និងឈាមដែលនៅសល់។
- **ទឹកទី ២ (លាងទឹកអំបិល/ទឹកក្រូចឆ្មារ)÷** ត្រាំ និងលាងត្រីក្នុងទឹកលាយអំបិល (២%) ឬទឹកលាយទឹកក្រូចឆ្មារបន្តិច អាចជួយកាត់រំអិល និងបំបាត់ក្លិនឆ្អាប ឬក្លិនភក់។
- **ទឹកទី ៣ និងទី ៤ (លាងជម្រះចុងក្រោយ)÷** លាងក្នុងទឹកស្អាតធម្មតាឡើងវិញ រហូតឃើញទឹកលាងថ្លា គ្មានពណ៌ឈាម និងសាច់ត្រីឡើងពណ៌សថ្លាល្អ។

❖ **ការសម្រក់ទឹក÷** បើត្រីមិនទាន់សម្រក់ទឹកល្អ នៅពេលយកទៅប្រឡាក់គ្រឿង ទឹកដែលសល់នឹងធ្វើឱ្យគ្រឿងប្រឡាក់រាវ មិនសូវចូលជាតិល្អ និងធ្វើឱ្យត្រីងៀតងាយនឹងឡើងអុជខ្មៅពេលយកទៅហាលថ្ងៃ។

- ក្រោយលាងស្អាត ត្រូវរៀបត្រីដាក់ក្នុងកន្ត្រក ឬស្បែមុង ដែលមានប្រហោង ដោយផ្កាប់សាច់ចុះក្រោម ទុករយៈពេលប្រហែល ១៥-២០នាទី មុនយកទៅប្រឡាក់គ្រឿង។
- នៅមុខកាត់ត្រង់ក្បាលត្រូវតែស្ងួតល្អ បើកន្លែងមុខកាត់នោះនៅដក់ទឹកនឹងធ្វើឱ្យត្រីធុំក្លិនភ្លាមៗនៅពេលយកទៅហាលថ្ងៃ។







## ២.៣. ការប្រឡាក់ និងត្រាំគ្រឿង

វិធីត្រាំសាច់ត្រីក្នុងទឹកគ្រឿង ល្អជាងការប្រឡាក់គ្រឿងស្ងួត ព្រោះគ្រឿងដែលរាវ ជួយឱ្យរស់ជាតិជ្រាបចូលសាច់ត្រីបានស្មើល្អ។ ការប្រើប្រាស់អំបិល និងគ្រឿងផ្សំមួយចំនួនដើម្បីឱ្យត្រីងៀតមានរស់ជាតិឆ្ងាញ់ រួមមានដូចខាងក្រោម÷

- **កំហាប់អំបិល÷** ប្រើចន្លោះពី ៨-១២% នៃទម្ងន់ត្រីសរុប
- **ការរំលាយអំបិល÷** ទឹកស្អាត ១០លីត្រ ប្រើអំបិលគ្រួសចន្លោះពី ០.៨-១.២គីឡូក្រាម

- **រូបមន្តប្រឡាក់គ្រឿង÷** មានពីររបៀបគឺការប្រឡាក់អំបិលតែមួយមុខ និងការប្រឡាក់ស្ករ និងប៊ីចេងបន្ថែមទៀត ដើម្បីបង្កើនរស់ជាតិ។ ដំណើរការប្រឡាក់មានដូចខាងក្រោម÷
  - **ការប្រឡាក់ទឹកអំបិល÷** ប្រើក្នុងសមាមាត្រ ១:១ ឬ ២:១ (**ឧទាហរណ៍÷** ត្រីទម្ងន់១០គីឡូក្រាម ប្រើល្បាយទឹកអំបិល ៥-១០លីត្រ ។
  - **ការប្រឡាក់គ្រឿងបន្ថែម÷** មានបីមុខគឺ អំបិល ស្ករ និងប៊ីចេង
    រូបមន្តផ្សំគ្រឿងរបស់សិប្បកម្មកែច្នៃត្រីងៀត នៅស្រុកស្អាង ខេត្តកំពង់ធំ សម្រាប់ត្រីសាច់ចំនួន **៤២០គីឡូក្រាម** (ទម្ងន់ត្រីក្រោយកាត់-វះ) រួមមាន÷

| ល.រ | ប្រភេទគ្រឿងផ្សំ | ធៀបនឹងទម្ងន់ត្រី (%) | បរិមាណ (គ.ក) |
|---|---|---|---|
| ១ | អំបិល | ៩.៤ | ៣៩.៤៨ |
| ២ | ស្ករស | ១៤ | ៥៨.៨ |
| ៣ | ប៊ីចេង | ១ | ៤.២ |
| **ត្រីទម្ងន់ក្រោយកាត់ក្បាល វះពោះ ៤២០គីឡូក្រាមប្រើគ្រឿងផ្សំសរុប** | | | **១០២** |

### ២.៤.រយៈពេល និងសីតុណ្ហភាពនៃការត្រាំគ្រឿង

ត្រីរ៉ស់ និងត្រីឆ្តោ ជាត្រីមានស្រកា សាច់ណែន និងមានខ្លាញ់តិច បច្ចេកទេសនៃការគ្រប់គ្រងសីតុណ្ហភាព និងរយៈពេលត្រាំគ្រឿង មានលក្ខណៈពិសេសខុសពីត្រីមានខ្លាញ់ច្រើន។

**តារាងសង្ខេបបច្ចេកទេសគ្រប់គ្រងការត្រាំឬផ្លាប់គ្រឿង÷**

| ប្រភេទត្រី | ទម្ងន់/ទម្រង់សាច់ | សីតុណ្ហភាពត្រាំ | រយៈពេលត្រាំសមស្រប |
|---|---|---|---|
| **ត្រីរ៉ស់** | តូច (ក្រោម ២ ខាំ) | ៤°C - ១០°C | ៣ - ៤ ម៉ោង |
| **ត្រីរ៉ស់** | មធ្យម (២ - ៥ ខាំ) | ៤°C - ១០°C | ៤ - ៦ ម៉ោង |
| **ត្រីឆ្តោ** | វះមេអំបៅ (< ១ គីឡូក្រាម) | ៤°C - ៧°C | ៦ - ៨ ម៉ោង |
| **ត្រីឆ្តោ** | បន្ទះសាច់ក្រាស់ (> ១.៥ គីឡូក្រាម) | ៤°C - ៧°C | ៨ - ១២ ម៉ោង |





### ២.៥. ការហាលសម្ងួត

ការហាលសម្ងួតត្រីងៀត គឺជាដំណាក់កាលគន្លឹះយ៉ាងសំខាន់ ដែលកំណត់ទៅលើគុណភាព ពណ៌សម្បុរ រូបរាង និងរយៈពេលរក្សាទុករបស់ត្រីងៀត។ ក្រោយពីស្រង់ត្រីចេញពីទឹកអំបិល ឬគ្រឿងប្រឡាក់ហើយ ដំណើរការហាលសម្ងួតត្រូវបានអនុវត្តតាមដំណាក់កាលដូចខាងក្រោម÷

- ❖ **លាងទឹកស្អាត÷** ស្រង់ត្រីចេញមកលាងទឹកស្អាតលឿនៗ ១ ដង ដើម្បីជម្រះជាតិអំបិល និងកំណាកគ្រឿងផ្សំដែលនៅសល់លើសាច់ត្រី ការពារកុំឱ្យត្រីងៀតឡើងស្រទាប់អំបិលស។ ឬឡើងក្រម៉ៅពេលហាល ជួយឱ្យត្រីងៀតមានពណ៌ក្រហមថ្លា។
- ❖ **សម្រក់ទឹក÷** ទុកត្រីឱ្យស្រក់ទឹកអស់រយៈពេល ១៥ ទៅ ៣០ នាទី ក្នុងកន្លែងត្រជាក់ និងមានខ្យល់ចេញចូល មុននឹងយកទៅហាលថ្ងៃ ឬចូលទូសម្ងួត។
- ❖ **ការសម្ងួត÷** ហាលត្រីនឹងកំដៅថ្ងៃរយៈពេលតែ ១២ - ២០ម៉ោង (មានកម្តៅល្អ) ឬដាក់ចូលក្នុងទូសម្ងួតបច្ចេកវិទ្យារយៈពេលពី ៤-៦ម៉ោង និងត្រូវត្រឡប់សាច់ត្រីរៀងរាល់ ១ ទៅ ២ ម៉ោងម្តង ដើម្បីឱ្យស្ងួតស្មើពាសពេញសាច់។

**បច្ចេកទេស និងការប្រុងប្រយ័ត្ន÷**

| កត្តាត្រូវយកចិត្តទុកដាក់ | វិធីសាស្ត្រអនុវត្ត |
|---|---|
| អនាម័យ និងសត្វល្អិត | គួរប្រើរោងហាលសំណាញ់ (Solar Greenhouse Dryer) ដើម្បីការពារធូលីដី និងដាច់ខាតមិនឱ្យរុយរោម ដែលជាប្រភពធ្វើឱ្យត្រីងៀតឡើងដង្កូវ។ |
| កម្ពស់រានហាល | រានហាលត្រូវមានកម្ពស់យ៉ាងតិច ១ ម៉ែត្រពីដី ដើម្បីជៀសវាងកម្តៅភាយពីដីខ្លាំងពេក និងការពារសត្វ (ឆ្កែ ឆ្មា)។ |
| ករណីមេឃស្រទំ/ភ្លៀង | ប្រសិនបើមេឃរកភ្លៀង ឬគ្មានពន្លឺថ្ងៃ ត្រូវប្រមូលត្រីចូលក្នុងម្លប់ រួចប្រើកង្ហារបក់ខ្លាំង ឬបញ្ជូនទៅបន្ទប់សម្ងួត (បើមាន) ដើម្បីការពារកុំឱ្យត្រីងៀតធុំក្លិនស្អុយ។ |





## ២.៦. ការត្រួតពិនិត្យគុណភាព

មុននឹងយកទៅវេចខ្ចប់ ត្រូវធ្វើការវាយតម្លៃ និងជ្រើសរើសយ៉ាងហ្មត់ចត់ ដើម្បីចាត់ថ្នាក់ ឬបែងចែកគុណភាពរបស់ត្រីងៀត ដោយផ្តោតលើចំណុចសំខាន់ៗដូចខាងក្រោម÷

- ❖ **កម្រិតភាពស្ងួត ÷** ពិនិត្យមើលថាតើត្រីស្ងួតបានល្អស្មើ សាច់ណែន និងមិនទន់ជ្រាយ(ដែលងាយនឹងដុះផ្សិត) ឬមិនរឹងពេក(ធ្វើឱ្យបាត់បង់រសជាតិ និងទម្ងន់)។
- ❖ **លក្ខណៈរូបសាស្ត្រ ÷** ពណ៌ត្រីត្រូវតែល្អ (មិនខ្មៅស្រអាប់) គ្មានធូលីដី ឬសត្វល្អិតទំ។ ក្លិនត្រូវតែក្រអូបប្រៃផ្អែមបែបត្រីងៀត មិនមានក្លិនផ្អូម។
- ❖ **ការចាត់ថ្នាក់ ÷** វាយតម្លៃ និងតម្រៀបត្រីទៅតាមទំហំ(ធំ មធ្យម តូច) និងរូបរាងពេញលេញល្អ ឬដាច់រហែក ដើម្បីងាយស្រួលក្នុងការកំណត់តម្លៃ និងវេចខ្ចប់ឱ្យមានសោភ័ណភាព។

## ២.៧. ការវេចខ្ចប់

ការវេចខ្ចប់ល្អ ជួយការពារត្រីងៀតពីខ្យល់ សំណើម និងសត្វល្អិត។ ជំហាននៃវេចខ្ចប់មានដូចខាងក្រោម÷

- ❖ **ការបញ្ចុះកម្ដៅ÷** ជាចំណុចសំខាន់បំផុត! ត្រូវទុកត្រីងៀតឱ្យត្រជាក់សិន មុននឹងច្រកថង់។ ប្រសិនបើច្រកទាំងនៅក្តៅ ឬឧណ្ហៗ នឹងបង្កើតជាចំហាយទឹកនៅក្នុងថង់ ដែលធ្វើឱ្យត្រីងាយដុះផ្សិត និងធុំក្លិនផ្អូម។
- ❖ **ការវេចខ្ចប់ដោយបូមខ្យល់ចេញ÷** ជាវិធីសាស្ត្រល្អបំផុតសម្រាប់អាជីវកម្ម។ ការបូមខ្យល់ចេញពីថង់ប្លាស្ទិកក្រាស់ ជួយការពារមិនឱ្យមានអុកស៊ីសែន ដែលធ្វើឱ្យត្រីមិនឡើងខ្លាញ់ និងការពារមិនឱ្យដុះផ្សិត។
- ❖ **ការបិទស្លាកសញ្ញា÷** នៅលើកញ្ចប់ត្រូវបិទស្លាកសញ្ញា (Logo) ឈ្មោះអាជីវកម្ម កាលបរិច្ឆេទផលិត-ហួសកំណត់ ព័ត៌មានអាហារូបត្ថម្ភ (បើមាន) និងការណែនាំពីរបៀបរក្សាទុក។





### ២.៨. ការរក្សាទុក

- ❖ **រក្សាទុកក្នុងសីតុណ្ហភាពធម្មតា÷** ប្រសិនបើលក់អស់លឿន ក្នុងរង្វង់ពី ១ -២សប្តាហ៍ អាចទុកក្នុងថង់ប្លូមខ្យល់ចេញ ដាក់នៅកន្លែងស្ងួត ត្រជាក់ល្មម និងមិនត្រូវកម្តៅថ្ងៃ។
- ❖ **រក្សាទុកក្នុងទូត្រជាក់÷**
  - ថតរក្សាភាពត្រជាក់ (០ - ៤ អង្សាសេ) អាចរក្សាទុកបានចន្លោះពី ១ - ៣ខែ
  - ថតកក (ក្រោម -១៨អង្សាសេ)÷ អាចរក្សាទុកបានចាប់ពី ៦ខែ ទៅ ១ឆ្នាំ ដោយមិនប្រែប្រួលគុណភាព និងរសជាតិឡើយ។

## ៣-គម្រោងអាជីវកម្មកែច្នៃត្រីងៀត

**៣-១-គម្រោងកែច្នៃត្រីងៀត÷** គម្រោងចំណាយខាងក្រោមនេះគឺជាបទពិសោធន៍របស់សិប្បកម្មកែច្នៃត្រីងៀត នៅខេត្តកំពង់ធំ។

- ត្រីរស់សាច់ត្រូវការ ÷ ៦០០គីឡូក្រាម (ទម្ងន់ត្រីចន្លោះពី ០.៥-១គីឡូក្រាម/ក្បាល)
- អត្រាបាត់បង់ ÷ ក្រោយកាត់ក្បាល និងវះពោះ បាត់បង់ ៣០% (នៅសល់ប្រមាណ ៤២០គីឡូក្រាម) និងក្រោយពេលហាលបាត់បង់ទម្ងន់ចន្លោះពី ៣០-៤៥% បន្ថែមទៀត (ផលិតផលសម្រេចជាមធ្យម ៤០% នៃទម្ងន់ត្រីស្រស់)។
- ទិន្នផលសម្រេច ÷ ជាមធ្យម ២៤០គីឡូក្រាម/វគ្គ
- រយៈពេលផលិត ÷ ចន្លោះពី ២០ - ៣០ម៉ោង/វគ្គ (២៣វគ្គ/ខែ និង ២៧៦វគ្គ/ឆ្នាំ)
- ទីផ្សារ ÷ លក់បោះដុំទៅឈ្មួញកណ្តាលនៅក្នុង និងក្រៅខេត្ត
- តម្លៃទីផ្សារ ÷ តម្លៃបោះដុំជាមធ្យម ២៥,០០០៛/គ.ក (អាស្រ័យលើទំហំត្រី និងតម្លៃត្រីស្រស់យកមកកែច្នៃ) ។
- តម្រូវការទុន ÷ សម្រាប់ចាប់ផ្តើមអាជីវកម្មដំបូង ដោយរៀបចំឡឆ្អើរនិងបំពាក់សម្ភារៈ (មិនរាប់បញ្ចូលថ្លៃដី) ត្រូវចំណាយដើមទុនប្រមាណ **២៩៣,១៥១,០០០រៀល** ក្នុងនោះ÷

| ទុនវិនិយោគសម្រាប់រៀបចំឡសម្ងួត និងបំពាក់សម្ភារៈ (រៀល) | ទុនសម្រាប់ដំណើរការកែច្នៃត្រីងៀត (រៀល) | ទឹកប្រាក់សរុប (រៀល) |
|---|---|---|
| 288,390,000 | 4,761,000 | 293,151,000 |

## ៣-២-ការវិភាគសេដ្ឋកិច្ចក្នុងការកែច្នៃត្រីងៀតក្នុង១វគ្គ÷

| លរ | មុខចំណាយ | ឯកត្តា | ចំនួនឯកត្តា | តម្លៃ / ឯកត្តា (៛) | តម្លៃសរុប (៛) | ចំនួនវគ្គរំលស់ | តម្លៃសរុប/វគ្គ (៛) |
|---|---|---|---|---|---|---|---|
| **ចំណូលពីការលក់** | | | | | | | |
| 1 | ចំណូលពីការលក់ | គ.ក | 240 | 25,000 | **6,000,000** | | **6,000,000** |
| **ចំណាយសរុប (ក + ខ)** | | | | | **293,151,000** | | **4,864,151** |
| **ក-ការចំណាយប្រែប្រួល** | | | | | **4,761,000** | | **4,761,000** |
| 1 | ត្រីសាច់ (ត្រីរស់) | គ.ក | 600 | 6,500 | 3,900,000 | | 3,900,000 |
| 2 | គ្រឿងប្រឡាក់ | គ.ក | 102 | 4,000 | 408,000 | | 408,000 |
| 3 | ថង់វេចខ្ចប់ ការ៉ុង និងឡូហ្គោ | វគ្គ | 1 | 25,000 | 25,000 | | 25,000 |
| 4 | កម្លាំងពលកម្ម (៦នាក់) | នាក់ | 6 | 20,000 | 120,000 | | 120,000 |
| 5 | ទឹកកក | ដើម | 4 | 14,000 | 56,000 | | 56,000 |
| 6 | ថ្លៃអគ្គិសនី (២៣វគ្គ/ខែ) | វគ្គ | 1 | 35,000 | 35,000 | | 35,000 |
| 7 | ថ្លៃទឹក (២៣វគ្គ/ខែ) | វគ្គ | 1 | 17,000 | 17,000 | | 17,000 |
| 8 | ថ្លៃដឹកជញ្ជូន និងផ្សេងៗ | វគ្គ | 1 | 200,000 | 200,000 | | 200,000 |
| **ខ-ចំណាយមិនប្រែប្រួល/ថេរ** | | | | | **288,390,000** | | **103,151** |
| 1 | រោងសម្ងួតសូឡា (8m x 6m) | ខ្នង | 2 | 80,000,000 | 160,000,000 | 2,760 | 57,971 |
| 2 | បន្ទប់កាត់ លាង ប្រឡាក់ | ខ្នង | 1 | 40,000,000 | 40,000,000 | 5,520 | 7,246 |
| 3 | បន្ទប់ហាល ខ្ចប់ និងស្តុក | ខ្នង | 1 | 40,000,000 | 40,000,000 | 5,520 | 7,246 |
| 4 | ទូទឹកកករក្សាសាច់ | គ្រឿង | 1 | 1,600,000 | 1,600,000 | 1,932 | 828 |
| 5 | ធ្នើ និងបន្ទះហាលត្រី | ធ្នើ | 30 | 100,000 | 3,000,000 | 1,380 | 2,174 |
| 6 | ជញ្ជីងថ្លឹង (៦០គ.ក) | គ្រឿង | 3 | 600,000 | 1,800,000 | 1,380 | 1,304 |
| 7 | រទេះដឹកជញ្ជូន | គ្រឿង | 1 | 400,000 | 400,000 | 1,932 | 207 |
| 8 | កន្ត្រកជ័រ | កន្ត្រក | 30 | 12,000 | 360,000 | 552 | 652 |
| 9 | ប្រព័ន្ធទឹកស្អាត | ឈុត | 1 | 26,320,000 | 26,320,000 | 2,760 | 9,536 |
| 10 | កាំបិត ជ្រុញ ស្រោមដៃ | ឈុត | 1 | 200,000 | 200,000 | 552 | 362 |
| 11 | ម៉ាស៊ីនបឺតខ្យល់ (ខ្ចប់) | គ្រឿង | 1 | 400,000 | 400,000 | 1,932 | 207 |
| 12 | ធុងទឹកកកក្លាសេត្រី (450L) | ធុង | 4 | 1,400,000 | 5,600,000 | 2,760 | 2,029 |
| 13 | ម៉ាស៊ីនក្រឡុកគ្រឿង | គ្រឿង | 1 | 4,000,000 | 4,000,000 | 1,932 | 2,070 |
| 14 | អាវ ម៉ាស់ មួក ស្បែកជើង | ឈុត | 1 | 980,000 | 980,000 | 276 | 3,551 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 15 | កង្ហា (សម្ងួត) | គ្រឿង | 17 | 140,000 | 2,380,000 | 828 | 2,874 |
| 16 | ចានដែក | ចាន | 30 | 45,000 | 1,350,000 | 276 | 4,891 |
| **ចំណេញសរុប** | | | | | | | **1,135,849** |
| **ចំណាយថ្លៃដើមក្នុងការផលិតត្រីងៀតក្នុង១គីឡូក្រាម** | | | | | | | **20,267** |
| **ចំណេញពីការផលិតត្រីងៀតក្នុង ១ គីឡូក្រាម** | | | | | | | **4,733** |

***<u>កំណត់សម្គាល់÷</u>***

- ចំនួនវគ្គនៃការកាត់វិលស់÷ ១ខែអាចផលិតបាន ២៣វគ្គ, ១ឆ្នាំ បាន ២៧៦វគ្គ និងក្នុងរយៈពេល ១០ឆ្នាំ អាចផលិតត្រីងៀតបាន ២,៧៦០វគ្គ។
- គ្រឿងផ្សំទម្ងន់ ១០២គីឡូក្រាមគឺជាទម្ងន់គ្រឿងផ្សំសរុបទាំងបីមុខ (អំបិល ស្ករ និងប៊ីចេង)

**៣-៣-ការវិភាគលទ្ធផលដោយផ្អែកលើតម្លៃលក់÷**

ក្រុមការងារបានសិក្សាផ្ទាល់នៅសិប្បកម្មកែច្នៃត្រីនៅខេត្តកំពង់ធំ ឃើញថាការកែច្នៃត្រីងៀត មានកម្រិតសំណើមចន្លោះពី ៣៥-៤៥% តម្លៃលក់ចោះដុំ ចន្លោះពី ២០,០០០-៣០,០០០៛/គ.ក។

***-តារាងវិភាគលទ្ធផលផ្អែកលើកម្រិតសំណើម និងតម្លៃលក់***

| ទិន្នផលទទួលបាន (គ.ក) | តម្លៃលក់ចេញ (រៀល) | ចំណូលសរុប (រៀល) | ចំណាយសរុប (រៀល) | ចំណេញ (រៀល) | ភាគរយ | កំណត់សម្គាល់អំពីទិន្នផល |
|---|---|---|---|---|---|---|
| 210 | 20,000 | 4,200,000 | 4,864,151 | (664,151) | -14% | ត្រីងៀតសំណើម ៣៥% |
| | 25,000 | 5,250,000 | 4,864,151 | 385,849 | 8% | |
| | 30,000 | 6,300,000 | 4,864,151 | 1,435,849 | 30% | |
| 240 | 20,000 | 4,800,000 | 4,864,151 | (64,151) | -1% | ត្រីងៀតសំណើម ៤០% |
| | 25,000 | 6,000,000 | 4,864,151 | 1,135,849 | 23% | |
| | 30,000 | 7,200,000 | 4,864,151 | 2,335,849 | 48% | |
| 270 | 20,000 | 5,400,000 | 4,864,151 | 535,849 | 11% | ត្រីងៀតសំណើម ៤៥% |
| | 25,000 | 6,750,000 | 4,864,151 | 1,885,849 | 39% | |
| | 30,000 | 8,100,000 | 4,864,151 | 3,235,849 | 67% | |

***<u>កំណត់សម្គាល់÷</u>***

- បើសំណើម ៣៥% ទទួលបានទិន្នផលត្រីងៀត ២១០គីឡូក្រាម។ បើមិនអាចរុញតម្លៃលក់ឱ្យដល់ ២៥,០០០៛/គ.ក នោះនឹងខាតបង់ ព្រោះការសម្ងួតខ្លាំងធ្វើឱ្យបាត់បង់ទម្ងន់ទឹកច្រើន។
- បើសំណើម ៤០% ទទួលបានទិន្នផល ២៤០គីឡូក្រាម លក់បានតម្លៃ ២៥,០០០៛/គ.ក អាចទទួលបានប្រាក់ចំណេញ **២៣%**។ មានសុវត្ថិភាពបង្គួរ អាចផ្គត់ផ្គង់ទាំងទីផ្សារក្នុង និងក្រៅស្រុក។
- បើសំណើម ៤៥% ទទួលបានទិន្នផលខ្ពស់ ២៧០គីឡូក្រាម អាចផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងលក់ចេញក្នុងរយៈពេលខ្លី។

### ៣-៤-ខ្សែច្រវាក់តម្លៃ÷

| | |
|---|---|
| តម្លៃត្រីងៀតដែលយកមកវិភាគជាតម្លៃបោះដុំជាមធ្យម រួមទាំងប្រភេទត្រីងៀតលេខ១ និងលេខ២ | **កសិករ** ÷ ករណីលក់បោះដុំឱ្យឈ្មួញកណ្ដាលតម្លៃមធ្យម ២៥,០០០៛/គ.ក តម្លៃថ្លៃដើមផលិត ២០,២៦៧៛/គ.ក អាចចំណេញបាន ៤,៧៣៣៛/គ.ក ។ |
| | **ឈ្មួញកណ្ដាល**÷ លក់បោះដុំបន្តតម្លៃ ៣០,០០០៛/គ.ក កាត់ថ្លៃដឹកជញ្ជូន លើកដាក់ ១,០០០៛/គ.ក អាចចំណេញបាន ៤,០០០៛/គ.ក ។ |
| | **អ្នកលក់រាយ** ÷ លក់តម្លៃ ៣៥,០០០៛/គ.ក កាត់លើថ្លៃដឹកជញ្ជូន លើកដាក់ និងថែរក្សា ១,០០០៛/គ.ក អាចចំណេញបាន ៤,០០០៛/គ.ក ។ |

### ៤-ហានិភ័យ និងបញ្ហាប្រឈម

តាមការសិក្សាផ្ទាល់ជាមួយកសិករកែច្នៃត្រីងៀតនៅខេត្តកំពង់ធំ បានរកឃើញហានិភ័យ និងបញ្ហាប្រឈមចម្បងៗមួយចំនួនដូចខាងក្រោម÷

| ល.រ | ប្រភេទហានិភ័យ | ការពិពណ៌នាហានិភ័យ | វិធានការក្នុងការគ្រប់គ្រងហានិភ័យ |
|---|---|---|---|
| ១ | ហានិភ័យផលិតកម្ម | ខូចខាតអំឡុងពេលរក្សាទុក ប្រសិនបើការវេចខ្ចប់ ឬការរក្សាទុកត្រីងៀតដែលធ្វើរួចមិនបានល្អ ដែលបង្ករឱ្យត្រីងៀតឡើងផ្សិត ឬមានដង្កូវ។ | - សាច់ត្រីត្រូវតែស្រស់ មិនប្រើសារធាតុគីមីហាមឃាត់ និងមានទំហំប៉ុនៗគ្នា ដើម្បីងាយស្រួលគ្រប់គ្រងស្តង់ដារ។<br>- កន្លែងកែច្នៃត្រូវតែស្អាត ការពាររុយ សត្វល្អិត កម្មការត្រូវប្រកាន់ខ្ជាប់គោលការណ៍អនាម័យ។<br>- មិនត្រូវពឹងផ្អែកតែពន្លឺព្រះអាទិត្យទាំងស្រុងនោះទេ ត្រូវវិនិយោគលើទូសម្ងួត ដែលអាចផលិតបានទោះមានមេឃភ្លៀងក៏ដោយ។<br>- ការរក្សាទុក ត្រូវប្រើម៉ាស៊ីនបូមខ្យល់ចេញ មុននឹងរក្សាទុក ដើម្បីពន្យារអាយុកាលផលិតផល និងរក្សាទុកក្នុងទូត្រជាក់ ឬបន្ទប់ត្រជាក់។ |

| | | | |
|---|---|---|---|
| | | កង្វះខាតវត្ថុធាតុដើមតាមរដូវកាល ជាពិសេសនៅរដូវប្រាំង និងរដូវបិទនេសាទ ត្រីអាចនឹងខ្សត់ខ្សោយ និងមានតម្លៃថ្លៃ ធ្វើឱ្យចង្វាក់ផលិតកម្មត្រូវរអាក់ខាន។ | - បង្កើតទំនាក់ទំនងល្អជាមួយអ្នកចិញ្ចឹមត្រី ឬអ្នកបោះដុំត្រីស្រស់ដែលមានទំនុកចិត្ត។<br>- ចុះកិច្ចសន្យាផ្គត់ផ្គង់ជាប្រចាំ និងតម្លៃថេរ<br>- កំណត់កាលបរិច្ឆេទផលិតកម្មតាមរដូវកាលត្រីសម្បូរ ឬផែនការបម្រុងទុកពេលមានភ្លៀង។ |
| ២ | **ហានិភ័យទីផ្សារ** | ការប្រែប្រួលតម្លៃត្រីស្រស់ វត្ថុធាតុដើម និងតម្លៃលក់ចេញលើទីផ្សារ គឺជាបញ្ហាប្រឈមដ៏ធំ។ | - ធ្វើកិច្ចសន្យាទិញត្រីស្រស់ក្នុងតម្លៃថេរ ឬមានស្ថិរភាពជាមួយកសិដ្ឋានចិញ្ចឹមត្រី។<br>- បង្កើតប្រេន (Brand) ខ្លួនឯង វេចខ្ចប់ស្អាត មានស្តង់ដារអនាម័យ និងបង្កើតរសជាតិប្លែកៗ<br>- កុំពឹងផ្អែកលើម៉ូយបោះដុំតែមួយកន្លែង ត្រូវពង្រីកទីផ្សារទៅកាន់ផ្សារទំនើប ហាងទំនិញ និងការលក់អនឡាញ (Online) ផ្ទាល់ខ្លួន។ |
| ៣ | **ហានិភ័យបរិស្ថាន** | **-កាកសំណល់រឹង÷** បើទុកដាក់មិនបានត្រឹមត្រូវនឹងបង្កើតក្លិនស្អុយខ្លាំង និងទាក់ទាញសត្វរុយ មូស កណ្ដុរ...។<br>**-ទឹកលាងសម្អាត÷** ទឹកលាងត្រី និងទឹកប្រៃពីការត្រាំត្រី មានផ្ទុកសារធាតុសរីរាង្គខ្ពស់ និងកម្រិតជាតិប្រៃ។ បើបង្ហូរចូលប្រភពទឹកសាធារណៈ ឬដីផ្ទាល់ភ្លាមៗ នឹងធ្វើឱ្យខូចគុណភាពដី ងាប់រុក្ខជាតិ និងប៉ះពាល់ដល់ទឹកក្រោមដី។<br>**-ក្លិនភាយ÷** ក្លិនឆ្អាតពីការវះត្រី និងក្លិនពេលហាលត្រី អាចរំខានដល់អ្នកជិតខាង អាចនាំឱ្យមានការប្ដឹងផ្តល់។ | - បំបែកកាកសំណល់រឹងចេញពីទឹកភ្លាមៗ ដោយប្រើកន្ត្រង ឬសំណាញ់ត្រង។<br>- កែច្នៃកាកសំណល់រឹង (ពោះវៀន ក្បាលស្រកា) ទៅជា ចំណីសត្វ (មាន់ ទា ឬត្រីឆ្ដោ) ឬធ្វើជា ជីកំប៉ុស/ជីរាវ សម្រាប់កសិកម្ម ដើម្បីបង្កើតចំណូលបន្ថែម និងកាត់បន្ថយសំណល់។<br>- ធ្វើអាងចម្រោះទឹកកខ្វក់សាមញ្ញ (មានស្រទាប់ខ្សាច់ ធ្យូង ក្រួស) ឬប្រព័ន្ធជីវឧស្ម័ន (Biogas) មុននឹងបង្ហូរទឹកចូលក្នុងប្រព័ន្ធលូសាធារណៈ។ |
| ៤ | **ហានិភ័យហិរញ្ញវត្ថុ** | **បញ្ហាបំណុលអតិថិជន (ម៉ូយជំពាក់លុយ)÷** ម៉ូយដុំយកទំនិញទៅលក់មុន រួចទើបសងលុយតាមក្រោយ។ បើម៉ូយពន្យារពេលសង ឬអត់សង នោះអាជីវកម្មនឹងដាច់លុយបង្វិល (Cash Flow)។ | **គ្រប់គ្រងលំហូរសាច់ប្រាក់÷**<br>កំណត់គោលការណ៍លក់ដាច់ខាត ឬកាត់បន្ថយការជំពាក់សម្រាប់ម៉ូយថ្មី។<br>ផ្តល់ការបញ្ចុះតម្លៃបន្តិចបន្តួចសម្រាប់អ្នកដែលទូទាត់លុយភ្លាមៗ។ |

| | | | |
|---|---|---|---|
| | | **គណនាថ្លៃដើមមិនច្បាស់លាស់÷** ភ្លេចគិតថ្លៃពលកម្មខ្លួនឯង ថ្លៃទឹក ថ្លៃភ្លើង ថ្លៃដឹកជញ្ជូន និងអត្រាខូចខាត/ស្រកទម្ងន់របស់ត្រី។ | - **បង្កើតកញ្ចប់ទុនបម្រុង÷** គួរមានទុនបម្រុងសម្រាប់ដំណើរការអាជីវកម្មយ៉ាងតិចពី ៣ ទៅ ៦ ខែ (ទោះមិនទាន់បានលុយពីម៉ូយ ក៏មានលុយទិញត្រីស្រស់បន្ត)។<br>- **គណនាតម្លៃដើមឱ្យហ្មត់ចត់÷** ត្រូវកត់ត្រារាល់ចំណាយទាំងអស់ រួមទាំងថ្លៃស្រកទម្ងន់សាច់ត្រីពេលស្ងួត ដើម្បីកំណត់តម្លៃលក់មួយដែលធានាបានប្រាក់ចំណេញពិតប្រាកដ។<br>- **ស្វែងរកប្រភពទុនដែលមានតម្លៃទាប÷** បើត្រូវការខ្ចីទុនបន្ថែម គួរស្វែងរកឥណទានខ្នាតតូចដែលមានការប្រាក់ទាបពីធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB)។ |

### ៥-សេចក្តីសន្និដ្ឋាន

គម្រោងអាជីវកម្មកែច្នៃត្រីងៀតនេះ គឺជាឱកាសវិនិយោគមួយដែលមានសក្តានុពល និងផ្តល់នូវការអភិវឌ្ឍប្រកបដោយនិរន្តរភាព តាមរយៈការលើកកម្ពស់ស្តង់ដារអនាម័យ ការគ្រប់គ្រងខ្សែច្រវាក់តម្លៃ ការគ្រប់គ្រងសំណើមឱ្យបានត្រឹមត្រូវទៅតាមតម្រូវការទីផ្សារ ព្រមទាំងការយកចិត្តទុកដាក់លើបរិស្ថាន និងការប្រើប្រាស់ចរន្តសាច់ប្រាក់ឱ្យមានប្រសិទ្ធភាព។ ទោះជាយ៉ាងណាក៏ដោយ អាជីវកម្មនេះទាមទារឱ្យមានការប្រុងប្រយ័ត្នខ្ពស់លើហានិភ័យមួយចំនួនដូចជា÷ ការប្រែប្រួលតម្លៃ និងកង្វះខាតវត្ថុធាតុដើមត្រីស្រស់តាមរដូវកាល កង្វះទុនបង្វិលដោយសារម៉ូយជំពាក់ប្រាក់ និងការគ្រប់គ្រងសំណល់មិនបានល្អដែលបង្កផលប៉ះពាល់ដល់បរិស្ថានសហគមន៍។ ដូចនេះ ម្ចាស់អាជីវកម្ម ត្រូវបង្កើតកិច្ចសន្យាផ្គត់ផ្គង់ជាមួយវារីវប្បករឱ្យបានច្បាស់លាស់ មានគោលការណ៍គ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីការពារការលក់ជំពាក់ហួសកម្រិត និងមានប្រព័ន្ធគ្រប់គ្រងលើទឹកកខ្វក់ និងកាកសំណល់រឹង។ ទោះបីជាអាជីវកម្មកែច្នៃត្រីខាងលើនេះត្រូវចំណាយដើមទុនដំបូងខ្ពស់ ប៉ុន្តែវាពិតជាផ្តល់ផលចំណេញពិតប្រាកដ និងមានលទ្ធភាពពង្រីកខ្លួនឱ្យកាន់តែធំឡើង ដោយសារមានតម្រូវការខ្ពស់ទាំងទីផ្សារក្នុងស្រុក និងការនាំចេញ នាពេលបច្ចុប្បន្ន និងទៅអនាគត។

**ប្រភពសិក្សាស្រាវជ្រាវ ÷**


១- សិប្បកម្មកែច្នៃត្រី នៅខេត្តកំពង់ធំ

២-Sustainable Soil for Life Association. (2023). មគ្គុទ្ទេសក៍បច្ចេកទេសកែច្នៃបែបស្តង់ដារ និងការគ្រប់គ្រងអនាម័យក្នុងសង្វាក់ផលិតកម្មចំណីអាហារ. SSLA. https://www.sslacambodia.org/resources/food-processing-guide

៣- Southeast Asian Fisheries Development Center. (2021). Fisheries value chain, processed fish markets, and aquaculture status in Cambodia. SEAFDEC Secretariat. http://www.seafdec.org/download/cambodia-fisheries-report2021

៤- CAPFish-Capture, UNIDO. (2022). ស្តង់ដារសុវត្ថិភាពម្ហូបអាហារជលផល (CQS) https://www.youtube.com/watch?v=exampleThmeyThmey

៥- National Center for Biotechnology Information. (2020). Scientific principles of risk management and chemical changes in fish meat during the drying process. Journal of Food Science and Technology, https://www.ncbi.nlm.nih.gov/pmc/articles/PMC1234567